**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្តបាត់ដំបង
ស្រុកសង្កែ
ឃុំវត្តតាមិម
លេខៈ..៣៤..១...សជណ

# សេចក្តីជូនដំណឹង

-យោងទៅលើការកើនឡើងនៃគ្រោះថ្នាក់ចរាចរណ៍ អំពើហិង្សាក្នុងគ្រួសារ ការចុះខ្សោយសុខភាព ការបោះបង់ការសិក្សា ដែលបង្កឡើងដោយការពិសារគ្រឿងស្រវឹង។

-យោងស្មារតីអង្គប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំវត្តតាមិមថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៥ បានចេញសេចក្តីជូនដំណឹងដល់ប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានឃុំវត្តតាមិម។

១ ប្រជាពលរដ្ឋទាំងពីរភេទមិនត្រូវពិសារគ្រឿងស្រវឹងហើយធ្វើអំពើណាដែលប៉ះពាល់ដល់ខ្លួនឯង គ្រួសារព្រមទាំងអ្នកដទៃ។

២ បើពិសារគ្រឿងស្រវឹងត្រូវមានការប្រុងប្រយ័ត្ន ឬកុំបើកបរ។

៣ ពេលស្រវឹងស្រាមិនត្រូវប្រើអំពើហិង្សាក្នុងគ្រួសារ ស្រែកឡូឡា ឡៀតឡៀនកេរ្តិ៍ខ្មាស បំផ្លិចបំផ្លាញទ្រព្យសម្បត្តិខ្លួនឯង អ្នកដទៃ និងសាធារណៈ។

៤ ពេលផឹកស្រាស្រវឹងម្នាក់ឯង ឬច្រើនគ្នាមិនត្រូវស្រែកឡូឡា ឬដាក់គ្រឿងបំពងសម្លេងដែលរំខានដល់អ្នកដទៃក្នុងពេលសម្រាកចាប់ពីម៉ោង ២២:០០នាទីឡើងទៅ។

៥ ហាមលក់គ្រឿងស្រវឹង និងបង្ខំដល់ក្មេងក្រោមអាយុ ១៨ឆ្នាំ។

៦ ហាមលក់គ្រឿងស្រវឹងនៅក្នុងបរិវេណ វត្ត សាលារៀន មន្ទីរពេទ្យ។

៧ ជនណាដែលល្មើសក្នុងសេចក្តីជូនដំណឹងនេះត្រូវទទួលទោសជាកវិន័យទៅតាមច្បាប់រដ្ឋ។

សេចក្តីជូនដំណឹងដែលមានប៉ុន្មានចំណុចដូចខាងលើនេះ គឺដើម្បីទប់ស្កាត់ និងកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំវត្តតាមិមទាំងមូល និងមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ សូមអរគុណ!

វត្តតាមិម,ថ្ងៃទី២៨ ខែតុលា. ឆ្នាំ២០១៥

ជ. មេឃុំ

អ៊ុម ស្វាន